ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាជាតិកសិកម្មព្រែកលៀប



# ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរសជាតិ

ភ្នំពេញ មករា ២០០៧

# ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពរសជាតិ

*បទពិសោធន៍សម្រាប់បង្កើនទិន្នផលដំណាំ*

## រៀបចំដោយក្រុមពិសោធន៍ :


ផាត់ មុនី ប្រធានក្រុមពិសោធន៍ ដឹកនាំ និងកែសម្រួលរបាយការណ៍

សុខគុន គុនសុភ័ក្រ្ត សមាជិកក្រុមពិសោធន៍

ហួត ម៉ាលីម សមាជិកក្រុមពិសោធន៍



ម.ព.ឯ.ក AIDOC

Code: 176-001

Date:

Donated by:



សាលាជាតិកសិកម្មព្រែកលៀប មករា ២០០៧

# អារម្ភកថា

ការសិក្សាបានអនុវត្តក្នុងរូបភាពជាការពិសោធន៍សមូហកម្ម (Collection) ដំណាំចេកដែលបានមកពីពូជ ចំនួន ២៣ មុខ ។ កូនចេក ២៣ មុខនេះត្រូវបានបណ្តុះឡើងដោយជាលិកា និងនាំចូលមកពីប្រទេសបែលហ្ស៊ិក ។ តាមប្រវត្តិកូនចេកនាំចូលនេះ ភាគច្រើនមានប្រភពមកពីអាហ្វ្រិក ។ ដោយឡែកក្នុងការសិក្សានេះ ពូជចេកក្នុងស្រុកចំនួន ០៣ មុខក៏ត្រូវបានដាំសម្រាប់ជាកសិណ ។

គោលបំណងសំខាន់ក្នុងការសិក្សា គឺផ្តោតទៅលើភាពស៊ាំក្សេត្រ-បរិស្ថានក្នុងការលូតលាស់ ការផ្តល់ផល និងគុណភាពរស់ជាតិផ្លែចេករបស់ដំណាំចេកទាំង ២៦ ពូជ ។ ទន្ទឹមនេះដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការព័ត៌មាន សំខាន់ៗពាក់ព័ន្ធនឹងលក្ខណៈជីវសាស្ត្ររបស់ដំណាំចេកទូទៅ ទិន្នន័យនិងព័ត៌មានសំខាន់ៗដែលកើតមានក្នុងកម្លុងពេលពិសោធន៍ត្រូវបានប្រមូល វិភាគតាមស្ថិតិវិទ្យា និងចងក្រងជារបាយការណ៍នេះឡើង ។

របាយការណ៍នេះគ្រាន់តែជាមូលដ្ឋានព័ត៌មានដើមក្នុងតំបន់និងពេលវេលាកំណត់មួយប៉ុណ្ណោះ ដែលទាមទារការសិក្សាបន្តទៀត ។ ដូច្នេះគ្រប់មតិយោបល់ផ្សេងៗពាក់ព័ន្ធ នឹងលទ្ធផល វិធីសាស្ត្រពិសោធន៍ ក៏ដូចជាខ្លឹមសាដែលបានអធិប្បាយក្នុង របាយការណ៍នេះ ត្រូវបានស្វាគមន៍យ៉ាងកក់ក្តៅ ។

ក្រុមពិសោធន៍សាលាជាតិកសិកម្មព្រែកលៀប

ភ្នំពេញ, មករា ២០០៧

# មាតិកា

ទំព័រ

១.ស្ថានភាពទូទៅ ....................................................................01

២. វិធីសាស្ត្រពិសោធន៍ ....................................................................0៣

២.១. ទីកន្លែងនិងពេលវេលា ....................................................................0៣

២.២ អំពីប្រភេទដី ....................................................................0៣

២.៣ វិធីសាស្ត្រពិសោធន៍ ....................................................................0៣

២.៤ ការរៀបចំប្លុកពិសោធន៍ ....................................................................0៣

២.៥ ការងារអនុវត្តន៍ ....................................................................0៦

២.៥.១ ពូជ ....................................................................0៦

២.៥.២ ការរៀបចំដី .................................................................... 0៦

២.៥.៣ ការដាំដុះ ....................................................................0៧

២.៥.៤ ការស្រោចស្រព ....................................................................0៧

២.៥.៥ ការថែទាំ ....................................................................0៧

២.៥.៦ ការដាក់ជី ....................................................................0៧

៣ លទ្ធផល និងការពិភាក្សា ....................................................................0៨

៣.១ លទ្ធផល

៣.១.១ កំពស់ដើម ....................................................................0៨

៣.១.២ ប្រវែងស្លឹក ....................................................................0៩

៣.១.៣ ចំនួនស្លឹក .................................................................... ១១

៣.១.៥ ចំនួនផ្លែក្នុង ១ស្និត .................................................................... ១៣

៣.១.៦ ចំនួនផ្លែក្នុង ១ ស្ទង ....................................................................១៥

៣.១.៧ ចំនួនកូនបែក ....................................................................១៦

៣.១.៨ រយៈពេលចាប់ពីថ្ងៃដាំរហូតដល់ចេញត្រយូង ....................................................................១៧

៣.១.៩ រយៈពេលចាប់ពីថ្ងៃដាំធ្លាក់ត្រយូងរហូតដល់ទុំ ....................................................................១៩

៣.១.១០ រយៈពេលចាប់ពីថ្ងៃដាំរហូតដល់ទុំ ....................................................................២០

៣.១.១១ ទម្ងន់ផ្លែក្នុងមួយផ្លែ ....................................................................២១

៣.១.១២ ទម្ងន់ផ្លែក្នុងមួយស្ទង ....................................................................២៣

៣.២ ពិភាក្សា ....................................................................២៤

សេចក្តីសន្និដ្ឋាន....................................................................២៥

## ខ្លឹមសារសង្ខេប

ការសិក្សាដំណាំចេកត្រូវបានអនុវត្តនៅក្នុងសាលាជាតិកសិកម្មព្រែកលៀបដែលចាប់ផ្តើមពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥ ដល់ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦ ។ ការរៀបចំប្លង់ពិសោធន៍ត្រូវបានរៀបចំឡើងដោយ ចាប់ឆ្នោតដោយពេញលិញ (RCBD) ដែលមាន ៣ គុម្ព ២៦ ពូជ ដោយដាំក្នុងទំហំប្លុក ៤ ម × ៣ ម ហើយក្នុង ១ ប្លុកមាន ៣ ដើម និងមាន ២៦ ពូជ ។ ការស្រង់ទិន្នន័យគឺមាន : កំពស់ដើម ប្រវែងស្លឹក ចំនួនស្លឹក ចំនួនកូនបែក, ថ្ងៃខែចេញត្រយូង រយះពេលលូតលាស់ពីដាំដល់ផ្លែ ទម្ងន់ផ្លែក្នុង១ផ្លែ ទម្ងន់ផ្លែក្នុង១ស្ទង គិតជាគីឡូក្រាម ប្រវែងផ្លែ គិតជាសង់ទីម៉ែត្រ ចំនួនផ្លែក្នុង១ស្និតនិង ចំនួនស្និតក្នុង ១ ស្ទង ។

**លទ្ធផលពិសោធន៍បានបង្ហាញឱ្យឃើញថា :**

- ពូជដែលមានកំពស់ខ្ពស់ជាងគេគឺ ពូជលេខ ២៥ ហើយពូជដែលមាន កំពស់ទាបជាងគេគឺ ពូជលេខ ១២
- ពូជដែលមានប្រវែងស្លឹកវែងជាងគេគឺពូជលេខ ១១ ហើយពូជដែលមានកំពស់ទាបជាងគេគឺ ពូជលេខ ១៥
- ពូជដែលមានចំនួនស្លឹកច្រើនជាងគេគឺពូជលេខ ២ ហើយពូជដែលមានចំនួនស្លឹកតិចជាងគេគឺពូជលេខ ២១
- ពូជដែលមានប្រវែងផ្លែវែងជាងគេគឺពូជលេខ ១៨ ហើយពូជដែលមានប្រវែងផ្លែខ្លីជាងគេគឺពូជលេខ ២៤
- ពូជដែលមានចំនួនផ្លែច្រើនជាងគេគឺពូជលេខ ១៣ ហើយពូជដែលមានចំនួនផ្លែតិចជាងគេគឺពូជលេខ ១៣
- ពូជដែលមានចំនួនកូនបែកច្រើនជាងគេគឺពូជលេខ ៧ ហើយពូជដែលមានចំនួនកូនបែកតិចជាងគេគឺពូជលេខ ៣ និងពូជលេខ ១២
- ពូជដែលមានចំនួនថ្ងៃពីធ្លាក់ត្រយូងដល់ទុំ ឃើញថាពូជដែលមានចំនួនថ្ងៃវែងជាងគេគឺពូជលេខ ១៣ ហើយពូជដែលមានចំនួនថ្ងៃខ្លីជាងគេគឺ ពូជលេខ ៣ និងពូជលេខ ២៣
- ពូជដែលមានចំនួនថ្ងៃចាប់ពីដាំរហូតដល់ចេញត្រយូង ឃើញថាពូជដែលមានចំនួនថ្ងៃវែងជាងគេគឺពូជលេខ ១១ ហើយពូជ ដែលមានចំនួនថ្ងៃខ្លីជាងគេគឺ ពូជលេខ ២៤
- ពូជដែលមានចំនួនថ្ងៃចាប់ពីដាំរហូតដល់ចេញត្រយូង ឃើញថាពូជដែលមានទម្ងន់ធ្ងន់ជាងគេគឺពូជលេខ ៥ ហើយពូជដែលមានទម្ងន់ស្រាលជាងគេគឺ ពូជលេខ ២
- ពូជដែលមានចំនួនថ្ងៃចាប់ពីដាំរហូតដល់ទុំ ឃើញថាពូជដែលមានរយះពេលវែងជាងគេគឺពូជលេខ ៦ ហើយពូជដែលមានរយះពេលខ្លីជាងគេគឺ ពូជលេខ ២ ។

ដូច្នេះការដាំចេកដែលចង់បានអាយុកាលខ្លី គួរយកពូជលេខ ២ បើចង់បានចេកដែលមានផ្លែវែងល្អ គួរយកពូជចេកលេខ ១៨ ចំពោះចំនួនផ្លែចេកច្រើនហើយផ្លែល្អក្នុង ១ ស្ទង គួរយកពូជលេខ ១៣ និងពូជដែលមានរសជាតិ ឆ្ងាញ់ជាងគេគឺ ពូជលេខ ៤ (រសជាតិផ្អែម ក្លិនក្រអូបឈ្ងុយស្រាល) ពូជលេខ ៧ (រសជាតិផ្អែមឈ្ងុយ) ពូជលេខ ១០ (រសជាតិផ្អែមឈ្ងុយ) ពូជលេខ ២០ (រសជាតិផ្អែមឈ្ងុយ) ពូជលេខ ១៥ (រសជាតិផ្អែមស្រាល) ។

# ពូជចេកផ្តល់ទិន្នផលខ្ពស់ និងគុណភាពសជាតិ

## ១. ស្ថានភាពទូទៅ

ដំណាំចេកស្ថិតនៅក្នុងគ្រួសារ Musaceae ។ ផ្លែចេកជាចំណីអាហារមួយដែលប្រជាពលរដ្ឋពិភពលោកនិយមបំផុត ។ គេអាចឃើញដើមចេកនៅគ្រប់ទីកន្លែងទាំងអស់ក្នុងប្រទេសកម្ពុជា ។

ចេកដែលពលរដ្ឋនិយមដាំច្រើនជាងគេមានចេកណាំវ៉ា ចេកអំបូង និង ចេកពងមាន់។ ក្រៅពីពូជទាំង ៣ នេះយើងសង្កេតឃើញប្រជាពលរដ្ឋដាំពូជផ្សេងៗទៀតដែរដូចជា : ចេកនួន ចេកទឹក ចេកស្នាប់មុខ ចេកជ្វា ចេកមាសស្នួន ចេកអត់គ្រាប់ ចេកគ្រយូងជាដើម ។

ចេកជាដំណាំហូបផ្លែមួយដែលប្រជាជនកម្ពុជាក៏ដូចជាមនុស្សនៅក្នុងពិភពលោកទាំងមូលនិយមបរិភោគ ជាបង្អែម ជាអាហារប្រចាំថ្ងៃបន្ទាប់បន្សំ និងកែច្នៃធ្វើជានំផ្សេងៗ ពិសេសជាអង្ករនៅប្រទេសមួយចំនួនក្នុងទ្វីបអាហ្វ្រិក ។

ចំពោះប្រទេសកម្ពុជា ប្រជាជនភាគច្រើនបរិភោគផ្លែចេកជាចំណីបន្ទាប់បន្សំ ឬ ជាបង្អែម ហើយក៏អាចកែច្នៃសំរាប់ធ្វើជាម្ហូបអាហាររួមផ្សំបានជាច្រើនផងដែរ ។ ផ្លែចេកផ្តល់ថាមពល និងជីវជាតិជាច្រើន ។ នៅក្នុងផ្លែចេកមានជីវជាតិ មួយចំនួនដែលរាងកាយយើងត្រូវការដូចជា កាល់ស្យូម ម៉ាញ៉េស្យូម ហ្វូស្វ័រ ស្ពាន់ធ័រ ។ល។

វេជ្ជសាស្ត្របានប្រើប្រាស់ចេកក្នុងការព្យាបាលជម្ងឺច្រើនមុខ ជាពិសេសមានឥទ្ធិពលល្អប្រសើរក្នុងការព្យាបាលជម្ងឺរលាកពោះវៀន ក្រពះ ធ្វើអោយជម្ងឺផ្សេងៗឆាប់ជាសះស្បើយ ហើយក៏អាចព្យាបាលជម្ងឺរលាកតំរងនោម រលាកសន្លាក់ឆ្អឹង និងជាចំណីយ៉ាងប្រសើរសំរាប់អ្នកជម្ងឺខ្វះឈាម ព្រោះក្នុងផ្លែចេកមានកំរិតជាតិដែកខ្ពស់ ។ ទន្ទឹមនឹងនេះផងដែរ ចេកបានត្រូវគេប្រើប្រាស់ក្នុងការព្យាបាលជម្ងឺរាគមួល ហើយដែលអាចផ្តល់ប្រសិទ្ធភាពបានយ៉ាងល្អប្រសើរ ។

ជាទូទៅ ដំណាំចេកអាចដុះលូតលាស់បានលើដីដែលមាន pH ពី ៤ ដល់ ៨ ។ ប៉ុន្តែជាការប្រសើរ ដីដែលមាន pH ពី ៦ ដល់ ៧.៥ គឺជាដីសមស្របសំរាប់ដំណាំនេះ និងអាចផ្តល់ផលខ្ពស់ ។

ចេកជាដំណាំមួយដែលត្រូវការដីដែលមានជីជាតិល្អ ពិសេសជាតិអាសូត និង ប៉ូតាស្យូម ។ ចេកអាចផ្តល់ទិន្នផលដល់ទៅ ៤០ តោនក្នុងមួយហិកតា ។ ដូច្នេះភាពចាំបាច់ណាស់សំរាប់ដំណាំនេះ គឺដីដែលមានជីជាតិច្រើន ឬជាការចាំបាច់ត្រូវដាក់ជីបន្ថែមឱ្យបានសមស្របតាមតម្រូវការរបស់ដំណាំនេះ ។

ដោយឡែកចំណាប់អារម្មណ៍នៃការប្រើប្រាស់ពូជចេកត្រូវបានកត់ត្រា ទៅតាមចំណង់ចំណូលចិត្តរបស់អ្នកបរិភោគ អាចមិនអាស្រ័យទៅនឹងទំហំនៃទិន្នផលទេ ។ បើប្រៀបធៀបទៅនឹងតម្លៃសេដ្ឋកិច្ច ពូជចេកមានគុណភាពអាចផ្តល់កំរៃខ្ពស់ជាងពូជដែលមានទិន្នផលខ្ពស់លើផ្ទៃដីមួយឯកតាដូចគ្នា ។ ប៉ុន្តែបច្ចុប្បន្ននេះពុំទាន់មានការសិក្សាណាមួយឱ្យបានច្បាស់តាមស្ថានភាពភូមិសាស្ត្រ និង ក្សេត្រ-បរិស្ថាន ថាពូជណាមួយអាចផ្តល់គុណភាពល្អដែលជាទីពេញចិត្ត និងផ្តល់ទិន្នផលខ្ពស់ឆ្លើយតបទៅនឹងបរិមាណត្រូវការនៅទីផ្សារនៅឡើយ ។ អាស្រ័យហេតុនេះ ក្រោមកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម (CARDI) កម្ពុជា សាលាជាតិកសិកម្មព្រែកលៀបបាន ទទួលពូជនាំចូលពីប្រទេសបែលហ្ស៊ិកចំនួន ២៣ ពូជមកសិក្សាពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្ម (CARDI) ។